ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

រដ្ឋសភា

គំរោងច្បាប់លេខ......១.........

ថ្ងៃទី.៣១...ខែតុលា..ឆ្នាំ២០១២.

សេចក្ដីព្រាង

# ច្បាប់

## ស្ដីពី

# ការគ្រប់គ្រងអាស៊ីដខ្លាំង

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលបំណងកំណត់អំពីការគ្រប់គ្រង ការត្រួតពិនិត្យអាស៊ីដខ្លាំងគ្រប់ប្រភេទ ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស។

**មាត្រា ២.-**

ច្បាប់នេះ មានគោលដៅកំណត់អំពីការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើស ដែលបង្កឡើង ដោយការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ហើយដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពគ្របដណ្ដប់លើការផលិត ការកែច្នៃ ការនាំចូល ការនាំចេញ ការវេចខ្ចប់ ការដឹកជញ្ជូន ការយកតាមខ្លួន ការចែកចាយ ការលក់ ការទិញ ការរក្សាទុក និងការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

អាស៊ីដខ្លាំងក្នុងច្បាប់នេះ សំដៅដល់អាស៊ីដ វត្ថុធាតុដើម និងធាតុផ្សំជាអាស៊ីដទាំងឡាយ ទោះជាល្បាយរាវ ឬរឹង ហើយមានប៉េហាស់(pH)ស្មើ ឬក្រោម៣(បី) ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស ដូចមានចុះនៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់នេះ លើកលែងអាស៊ីដស៊ុលហ្វួរិក ដែលជាល្បាយរាវ(សូលុយស្យុង) និងមានកំហាប់ ឬដង់ស៊ីតេក្រោម៣៣% ដែលប្រើប្រាស់សម្រាប់ចាក់អាគុយ។ តារាងឧបសម្ព័ន្ធនៃច្បាប់នេះ អាចកែប្រែដោយអនុក្រឹត្យ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រងអាស៊ីដខ្លាំង

**មាត្រា ៥.-**

ការផលិត ការកែច្នៃ ការនាំចូល ការនាំចេញ ការវេចខ្ចប់ ការដឹកជញ្ជូន ការយកតាមខ្លួន ការចែកចាយ ការលក់ ការទិញ ការរក្សាទុក និងការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវមានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ឬការកំណត់ដោយបទដ្ឋានគតិយុត្តផ្សេងទៀត។

**មាត្រា ៦.-**

ការចេញអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតទាក់ទងនឹងការនាំចូល ការនាំចេញ ការផលិត ការកែច្នៃ អាស៊ីដខ្លាំងគ្រប់ប្រភេទ ជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

ចំពោះអាស៊ីដខ្លាំងមាននៅក្នុងតារាងឧបសម្ព័ន្ធ ហើយដែលត្រូវយកទៅប្រើប្រាស់សម្រាប់វិស័យសុខាភិបាល គឺជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

**មាត្រា ៧.-**

បែបបទនិងលក្ខខណ្ឌនៃការលក់ ការទិញ ការរក្សាទុក ការចែកចាយ ការដឹកជញ្ជូន ការវេចខ្ចប់ ការយកតាមខ្លួន និងការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៨.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានច្បាប់អនុញ្ញាតឲ្យប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវប្រើប្រាស់អាស៊ីដខ្លាំងទាំងនោះឲ្យចំគោលដៅ និងត្រូវគោរពបទដ្ឋានបច្ចេកទេស ក្នុងកម្រិតសុវត្ថិភាពខ្ពស់បំផុត។

**មាត្រា ៩.-**

អាស៊ីដខ្លាំងគ្រប់ប្រភេទ ដូចមានចុះនៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់នេះ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់តែក្នុងគោលដៅបម្រើវិស័យឧស្សាហកម្ម សុខាភិបាល កសិកម្ម សិប្បកម្ម បច្ចេកទេស វិទ្យាសាស្ត្រ វិទ្យាសាស្ត្រស្រាវជ្រាវ ពិសោធន៍ ការធ្វើតេស្ត និងវិស័យផ្សេងទៀតដែលបម្រើផលប្រយោជន៍ខាងសេដ្ឋកិច្ច សង្គម និងបម្រើជីវភាពប្រចាំថ្ងៃដែលស្របច្បាប់។

# ជំពូកទី៣
# ការគាំពារជនរងគ្រោះដោយអាស៊ីដខ្លាំង

**មាត្រា ១០.-**

ក្នុងករណីមានជនរងគ្រោះដោយអាស៊ីដខ្លាំង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការបញ្ជូនជនរងគ្រោះទៅសង្គ្រោះជាបន្ទាន់ នៅមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬគ្រឹះស្ថានព្យាបាលសាធារណៈផ្សេងទៀតដែលស្ថិតនៅជិតបំផុត។

**មាត្រា ១១.-**

មណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬគ្រឹះស្ថានព្យាបាលសាធារណៈផ្សេងទៀត ត្រូវផ្តល់ការសង្គ្រោះ និងការព្យាបាលបឋម ដល់ជនរងគ្រោះដោយសារអាស៊ីដខ្លាំង ដោយឥតគិតថ្លៃ។

ការកំណត់កម្រិតពិការភាពនៃជនរងគ្រោះ ដោយសារអាស៊ីដខ្លាំង ជាសមត្ថកិច្ចរបស់គណៈ-កម្មការជំនាញដែលបង្កើតឡើងដោយក្រសួងសុខាភិបាល និងអនុលោមតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

រដ្ឋត្រូវផ្តល់ជំនួយសង្គ្រោះផ្នែកច្បាប់ ដល់ជនរងគ្រោះ ដោយសារអាស៊ីដខ្លាំង។

**មាត្រា ១២.-**

ការគាំពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មជនរងគ្រោះ ដោយអាស៊ីដខ្លាំងទៅក្នុងសហគមន៍ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ១៣.-**

រដ្ឋលើកទឹកចិត្តឲ្យមានការចូលរួម ពីសប្បុរសជន សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងពីវិស័យឯកជន ក្នុងការជួយគាំពារដល់ជនរងគ្រោះ ដោយសារអាស៊ីដខ្លាំង។

# ជំពូកទី៤
# ទោសប្បញ្ញត្តិ

**មាត្រា ១៤.-**

ជនណាដែលផលិត កែច្នៃ នាំចូល នាំចេញ វេចខ្ចប់ ដឹកជញ្ជូន យកតាមខ្លួន ចែកចាយ លក់ ទិញ រក្សាទុក និងប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដោយគ្មានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ឬមិនគោរពតាម

ការកំណត់របស់បទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវផ្តន្ទាទោសដូចខាងក្រោម៖

១- ពិន័យជាប្រាក់ពី៥០០.០០០(ប្រាំសែន)រៀលទៅ១.៥០០.០០០(មួយលានប្រាំសែន)រៀល ព្រមទាំងទោសបន្ថែម ដោយរឹបអូសអាស៊ីដខ្លាំង ក្នុងករណីដែលអាស៊ីដខ្លាំងនោះ មានទម្ងន់ក្រោម ៥០០(ប្រាំរយ)ក្រាម។

២- ពិន័យជាប្រាក់ពី១.៥០០.០០០(មួយលានប្រាំសែន)រៀលទៅ១០.០០០.០០០(ដប់លាន) រៀល ព្រមទាំងទោសបន្ថែម ដោយរឹបអូសអាស៊ីដខ្លាំង ក្នុងករណីដែលអាស៊ីដខ្លាំងនោះ មានទម្ងន់ចាប់ពី ៥០០(ប្រាំរយ)ក្រាមឡើងទៅ។

**មាត្រា ១៥.-**

នីតិបុគ្គលអាចប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមាន ចែងក្នុងមាត្រា ៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែង ក្នុងមាត្រា១៤ខាងលើនេះ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀលទៅ១០.០០០.០០០ (ដប់លាន)រៀល ក្នុងករណីដែលអាស៊ីដខ្លាំងនោះ មានទម្ងន់ក្រោម៥០០(ប្រាំរយ)ក្រាម។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០(ដប់លាន)រៀលទៅ៥០.០០០.០០០ (ហាសិបលាន)រៀល ក្នុងករណីដែលអាស៊ីដខ្លាំងនោះ មានទម្ងន់ចាប់ពី៥០០(ប្រាំរយ) ក្រាម ឡើងទៅ។

នីតិបុគ្គល ត្រូវទទួលទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោស បន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា ១៦.-**

អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាស៊ីដខ្លាំង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ។

ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារអស់មួយជីវិត ក្នុងករណីបទឧក្រិដ្ឋខាងលើត្រូវបានប្រព្រឹត្តដោយ មាន៖

១- ការគិតទុកជាមុន ឬការពួនស្ទាក់។

២- អំពើទារុណកម្ម ឬអំពើឃោរឃៅមុន ឬក្នុងពេលប្រព្រឹត្តអំពើសម្លាប់។

ចំពោះបទឧក្រិដ្ឋខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា២០៦(ទោសបន្ថែម:ប្រភេទនិង រយៈពេល)នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស។

**មាត្រា ១៧.-**

អំពើដែលបណ្ដាលឲ្យស្លាប់អ្នកដទៃ ដោយអចេតនា ដោយការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ឬការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀត តម្រូវក្នុងការគ្រប់គ្រងអាស៊ីដខ្លាំង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀលទៅ១០.០០០.០០០(ដប់លាន)រៀល។

ចំពោះបទមជ្ឈិមខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា២០៨(ទោសបន្ថែមៈប្រភេទនិងរយៈពេល)នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស។

**មាត្រា ១៨.-**

នីតិបុគ្គល អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា១៧ខាងលើនេះ។

នីតិបុគ្គល ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី២០.០០០.០០០(ម្ភៃលាន)រៀលទៅ៥០.០០០.០០០(ហាសិបលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា២០៩(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា ១៩.-**

ទារុណកម្ម និងអំពើឃោរឃៅដោយប្រើអាស៊ីដខ្លាំង ដែលប្រព្រឹត្តទៅលើបុគ្គលណាមួយ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១០(ដប់)ឆ្នាំទៅ២០(ម្ភៃ)ឆ្នាំ។

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំទៅ២៥(ម្ភៃប្រាំ)ឆ្នាំ កាលបើការប្រព្រឹត្តបទឧក្រិដ្ឋខាងលើនេះ នាំឲ្យមានការកាត់អវយវៈ ឬឲ្យមានពិការភាពជាអចិន្ត្រៃយ៍ ដល់ជនរងគ្រោះ។

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី២០(ម្ភៃ)ឆ្នាំទៅ៣០(សាមសិប)ឆ្នាំ កាលបើការប្រព្រឹត្តបទឧក្រិដ្ឋខាងលើ បណ្ដាលឲ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ឬនាំឲ្យមានអត្តឃាតរបស់ជននេះ។

ចំពោះបទឧក្រិដ្ឋខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា២១៦(ទោសបន្ថែមៈប្រភេទនិងរយៈពេល)នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស។

**មាត្រា ២០.-**

អំពើហិង្សាដោយចេតនាទៅលើអ្នកដទៃ ដោយប្រើអាស៊ីដខ្លាំង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤.០០០.០០០(បួនលាន)រៀលទៅ១០.០០០.០០០(ដប់លាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ កាលបើការប្រព្រឹត្តអំពើនេះ នាំឲ្យមានការកាត់អវយវៈ ឬឲ្យមានពិការភាពជាអចិន្ត្រៃយ៍ ដល់ជនរងគ្រោះ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់)ឆ្នាំទៅ២០(ម្ភៃ)ឆ្នាំ កាលបើអំពើនេះបណ្តាលឲ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់។

ចំពោះបទល្មើសខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា២២៩(ទោសបន្ថែមៈប្រភេទនិងរយៈពេល)នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស។

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវផ្តន្ទាទោសដូចបទមជ្ឈិមនេះដែរ។

**មាត្រា ២១.-**

អំពើដែលបង្កឲ្យមានរបួស ដោយអចេតនា ដោយការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ឬការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្ន ដែលច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀតតម្រូវក្នុងការគ្រប់គ្រងអាស៊ីដខ្លាំង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី២០០.០០០(ម្ភៃម៉ឺន)រៀលទៅ២.០០០.០០០(ពីរលាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០(មួយលាន)រៀលទៅ៦.០០០.០០០(ប្រាំមួយលាន)រៀល កាលបើការប្រព្រឹត្តនេះ នាំឲ្យមានការកាត់អវយវៈ ឬឲ្យមានពិការភាពជាអចិន្ត្រៃយ៍ ដល់ជនរងគ្រោះ។

ចំពោះបទមជ្ឈិមខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា២៣៧(ទោសបន្ថែមៈប្រភេទនិងរយៈពេល)នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស។

**មាត្រា ២២.-**

នីតិបុគ្គល អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា២១ខាងលើនេះ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀលទៅ២០.០០០.០០០(ម្ភៃលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា២៣៨(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា ២៣.-**

អំពើផលិតម្ហូបអាហារ ឬការអនុញ្ញាតឲ្យផលិតម្ហូបអាហារ ដោយប្រើអាស៊ីដខ្លាំង ខុសពីបទដ្ឋានបច្ចេកទេស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀលទៅ១០.០០០.០០០(ដប់លាន)រៀល។

**មាត្រា ២៤.-**

នីតិបុគ្គល អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែង ក្នុងមាត្រា២៣ខាងលើនេះ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០.០០០.០០០(ម្ភៃលាន)រៀលទៅ៥០.០០០.០០០(ហាសិបលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា ២៥.-**

ក្រោយពេលដែលច្បាប់នេះចូលជាធរមាន រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបាននិងកំពុងធ្វើអាជីវកម្មអាស៊ីដខ្លាំង ដោយគ្មានការអនុញ្ញាត ហើយដែលមានបំណងធ្វើអាជីវកម្មអាស៊ីដខ្លាំង ត្រូវបំពេញបែបបទ ដើម្បីស្នើសុំការអនុញ្ញាតធ្វើអាជីវកម្ម ស្របតាមច្បាប់ជាធរមាន។

**មាត្រា ២៦.-**

បទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៤នៃច្បាប់នេះ ត្រូវចាប់អនុវត្តក្រោយពេលមានអនុក្រឹត្យដូចមានកំណត់ក្នុងមាត្រា៧នៃច្បាប់នេះ។



## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកថា គ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១១
ក្នុងសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៤។
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១១

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

# តារាងឧបសម្ព័ន្ធ

## អាស៊ីដខ្លាំង(មាត្រា៤នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង)

**តារាងនេះមានៈ**

- ឈ្មោះអាស៊ីដខ្លាំងជាភាសាខ្មែរនិងជាភាសាអន្តរជាតិ
- អាស៊ីដខ្លាំង ទោះជាល្បាយរឹងឬជាល្បាយរាវ ដែលមាន pH ស្មើឬក្រោម៣(បី) ហើយបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុខភាពនិងអាយុជីវិតមនុស្ស
- រួមទាំងវត្ថុធាតុដើមនិងវត្ថុធាតុផ្សំជាសារធាតុអាស៊ីដខ្លាំង

| ភាសាខ្មែរ | ភាសាបារាំង | ភាសាអង់គ្លេសបែបអាមេរិកាំង | រូបមន្តគី |
|---|---|---|---|
| អាស៊ីដអ៊ីដ្រូអ៊ីយ៉ូឌីក | Acide iodhydrique | Hydroiodic acid | HI |
| អាស៊ីដអ៊ីដ្រូប្រូមិក | Acide bromhydrique | Hydrobromic acid | HBr |
| អាស៊ីដពែរក្លរិក | Acide perchlorique | Perchloric acid | $HClO_4$ |
| អាស៊ីដក្លរីឌ្រិក | Acide chlorhydrique | Hydrochloric acid | HCl |
| អាស៊ីដហ្លួយអរីឌ្រិក | Acide Fluoridrique | Hydrofluoric Acid | HF |
| អាស៊ីដស៊ុលហ្វួរិក | Acide sulfurique | Sulfuric acid | $H_2SO_4$ |
| អាស៊ីដនីទ្រិក | Acide nitrique | Nitric acid | $HNO_3$ |
| អាស៊ីដក្លរិក | Acide chlorique | Chloric acid | $HClO_3$ |
| អាស៊ីដប៉ារ៉ាតូលុយអែនស៊ុលហ្វូនិក | Acide para toluenesulfonique | p-Toluenesulfonic acid | $C_7H_8O_3S$ |
| អាស៊ីដប្រូមិក | Acide bromique | Bromic acid | $HBrO_3$ |
| អាស៊ីដពែរប្រូមិក | Acide perbromique | Perbromic acid | HBrO |
| អាស៊ីដអ៊ីយ៉ូឌីក | Acide iodique | Iodic acid | $HIO_3$ |
| អាស៊ីដពែរអ៊ីយ៉ូឌីក | Acide periodique | Periodic acid | $HIO_4$ |
| អាស៊ីដហ្លួយអូរ៉ូអង់ទីម៉ូនិក | Acide fluoroantimonique | Fluoroantimonic acid | $H[SbF_6]$ |
| អាស៊ីដម៉ាហ្សិក | Acide magique | Magic acid | $FSO_3HSbF$ |
| អាស៊ីដកាបូរ៉ាន | Acide carborane | Carborane acid | $H(CHB_{11}Cl_{1}$ |
| អាស៊ីដហ្លួយអូរ៉ូស៊ុលហ្វួរិក | Acide fluorosulfurique | Fluorosulfuric acid | $FSO_3H$ |
| អាស៊ីដទ្រីហ្វ្លិក | Acide Triflique | Triflic acid | $CF_3SO_3H$ |

